**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**

**និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ:០២.៩៧៣៩......

រាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧

## សេចក្តីណែនាំរួម

## ស្តីពី

## ការពង្រឹងវិន័យ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់កងកម្លាំង កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ចូលរួមក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៤ ឆ្នាំ២០១៧

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ នស/រកម /១២១៥ /០១៥ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យោងអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩
- យោងផែនការអន្តរស្ថាប័នលេខ ០០៩ ផ.ក /១៦ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧
- យោងប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យទី០៤ ខែមិថុនា ឆ្នាំ២០១៧ សមាជិក នៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិគ្រប់រូបមានសិទ្ធិចូលរួមក្នុងការបោះឆ្នោតដូចជាប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតទូទៅ ហើយសិទ្ធិនេះត្រូវបានកំណត់ក្នុងច្បាប់ ស្តីពីការបោះឆ្នោត និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតជាធរមាន ។

សមាជិក នៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ គឺជាកងកម្លាំងប្រដាប់អាវុធរបស់ជាតិមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវខ្ពស់លើកិច្ចការការពារបូរណភាពដែនដី ការពង្រឹងសន្តិសុខ សុវត្ថិភាព រក្សា

របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គមដោយប្រកាន់ខ្ជាប់នូវការគោរពវិន័យ និងមានគោលជំហរអព្យាក្រឹតឥតលម្អៀង លើកតម្កើងនីតិរដ្ឋ និងលើកស្ទួយការគោរពការពារសិទ្ធិមនុស្ស ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ។

ទន្ទឹមនេះ ក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ខាងមុខនេះ សមាជិកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិគ្រប់រូបត្រូវមានករណីយកិច្ចចាំបាច់ក្នុងការបង្កនូវបរិយាកាសនយោបាយល្អ ស្ងប់ស្ងាត់ និងត្រូវរួមចំណែកយ៉ាងសកម្មផ្តល់សន្តិសុខ សុវត្ថិភាព ការរក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អ ដើម្បីឲ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់មានដំណើរទៅប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គ្មានការបំភិតបំភ័យ ការគំរាមកំហែង និងអំពើហិង្សា ។

ដើម្បីសម្រេចទិសដៅនេះ គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ (គ.ស.អ) និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមធ្វើការណែនាំដូចខាងក្រោម ៖

## I. ការពង្រឹងវិន័យរបស់កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ

ក្នុងនាមជាមន្ត្រីអនុវត្តច្បាប់ សមាជិកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិគ្រប់រូបត្រូវមានឆន្ទៈ និងស្មារតីមោះមុត ចូលរួមយ៉ាងសកម្មក្នុងការរក្សាបរិយាកាសសន្តិសុខ ដោយឈរលើការទទួលខុសត្រូវខ្ពស់ចំពោះប្រទេសជាតិ និងខិតខំជម្រុញរាល់សកម្មភាព ដើម្បីរក្សាឲ្យបានសុខសន្តិភាព សុវត្ថិភាព និងស្ថិរភាពសង្គម និងចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ នៅពេលខាងមុខ ។

គ្រប់ដំណាក់កាលនៃការបោះឆ្នោត ហាមដាច់ខាតការយកតួនាទី សិទ្ធិអំណាច ក្នុងនាមជាកងកម្លាំងប្រដាប់អាវុធរបស់ជាតិ ដើរបំផុសបំផុល បំភិតបំភ័យ និងគំរាមកំហែងតាមគ្រប់រូបភាព បង្កឲ្យមានភាពវឹកវរ ផ្លូវបាត់សណ្តាប់ធ្នាប់ និងរបៀបរៀបរយ ជាពិសេសមិនត្រូវប្រើអំណាច ឬឥទ្ធិពលទៅប្រព្រឹត្តសកម្មភាពណាមួយ ដើម្បីគាំទ្រ ឬប្រឆាំងនឹងបេក្ខជនឈរឈ្មោះបោះឆ្នោត តំណាង ឬភ្នាក់ងារ សកម្មជន និងអ្នកគាំទ្ររបស់គណបក្សនយោបាយណាមួយឡើយ ។ គ្រប់សកម្មភាពប្រតិបត្តិការរបស់ខ្លួន គឺមិនត្រូវប្រើប្រាស់រូបភាពប្រដាប់អាវុធគគ្រឹកគគ្រេងដែលអាច នាំឲ្យមានការភាន់ច្រឡំ បង្កភាពភ្ញាក់ផ្អើលជ្រួលច្របល់ និងការភ័យខ្លាចក្នុងស្រទាប់មហាជន ។

ចំពោះសមាជិកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិគ្រប់ជាន់ថ្នាក់ដែលត្រូវបានចាត់ឲ្យបំពេញការកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវយកចិត្តទុកដាក់សហការអនុវត្តឲ្យបានម៉ឺងម៉ាត់ តាមគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ សេចក្តីណែនាំ ក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត និងបទបញ្ជានានា រួមទាំងការពង្រឹងវិន័យផ្ទៃក្នុងរបស់ខ្លួន ។

គ្រប់យន្តការ-រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតនៃរាជរដ្ឋាភិបាល និងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវសហការជាមួយលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតរបស់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អនុវត្តតាមផែនការអន្តរស្ថាប័នរបស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប សេចក្តីណែនាំរួម ផែនការសកម្មភាព និងបទបញ្ជានានាដែលពាក់ព័ន្ធដល់កិច្ចប្រតិបត្តិការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ទាំងមូល ។

## II. ការពង្រឹងភារកិច្ចរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត

ការផ្តល់សន្តិសុខ សុវត្ថិភាពដល់មុខសញ្ញា និងគោលដៅទាំងអស់ គឺតម្រូវឲ្យមានការរៀបចំការពារជារួមជាលក្ខណៈប្រយោល ឬមិនចំពោះ ពីព្រោះយើងមិនមានលទ្ធភាពប្រើប្រាស់កម្លាំងការពារផ្ទាល់សម្រាប់មុខសញ្ញា និងគោលដៅនីមួយៗទាំងអស់បានទេ ។ មុខសញ្ញា និងគោលដៅដែលត្រូវការពារជាអាទិភាព រួមមានៈ ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត អ្នកគាំទ្រ តំណាង ឬភ្នាក់ងារ និងបេក្ខជនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់ថ្នាក់ អ្នកសង្កេតការណ៍ជាតិ-អន្តរជាតិ ទីកន្លែងជួបជុំជាសាធារណៈ ក្បួនព្យុហយាត្រា ឬក្បួនដំណើរ

ដោយក្រុមថ្មើរជើង ឬដោយយានយន្តគ្រប់ប្រភេទរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទីកន្លែងរក្សាទុក ឬក្បួនដឹកជញ្ជូនសម្ភារឧបករណ៍ គ្រឿងសង្ហារិម និងឯកសារសម្រាប់ដំណើរការបោះឆ្នោតទាំងមូល ។

**១/ ដំណាក់កាលឃោសនាបោះឆ្នោត**

ការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ (រយៈពេល ១៤ថ្ងៃ) ត្រូវចាប់ផ្តើមពីថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៧ ហើយគ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំងអស់ ត្រូវបញ្ឈប់ ២៤ម៉ោង នៅមុនថ្ងៃបោះឆ្នោត ។

ត្រូវបែងចែកភ្នាក់ងារសន្តិសុខបោះឆ្នោត ការពារសកម្មភាពឃោសនាបោះឆ្នោតនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជាអាទិ៍: ការជួបជុំជាសាធារណៈ ក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានយន្តគ្រប់ប្រភេទនៅក្នុងមូលដ្ឋានឃុំ សង្កាត់ដែលគណបក្សមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដោយរក្សាឲ្យបាននូវបរិយាកាសនយោបាយល្អ គ្មានការប៉ះគិតប៉ះភ័យ ការគំរាមកំហែង អំពើហិង្សា និងចលាចល ឬការអុកឡុកវឹកវរផ្សេងៗ ។

ភ្នាក់ងារសន្តិសុខបោះឆ្នោត មិនត្រូវឈរ ឬដើរកៀកពេក ឬក៏ស្ថិតក្នុងបរិវេណនៃការជួបជុំជាសាធារណៈ ក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានយន្តគ្រប់ប្រភេទរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងត្រូវធានាចំពោះគ្រប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនូវសិទ្ធិស្មើៗគ្នាក្នុងការទទួលបានសេវាសន្តិសុខ សុវត្ថិភាព និងការរៀបចំរបៀបរៀបរយ និងសណ្តាប់ធ្នាប់សាធារណៈ ។ ភ្នាក់ងារសន្តិសុខបោះឆ្នោតដែលកំពុងបំពេញភារកិច្ចមិនត្រូវប្រឆាំង គាំទ្រ ឬចូលរួមសកម្មភាពឃោសនារបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬក៏បេក្ខជនណាមួយជាដាច់ខាត ។

**២/ ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

ថ្ងៃអាទិត្យទី ០៤ ខែមិថុនា ឆ្នាំ២០១៧ គឺជាថ្ងៃបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោតគ្រប់រូបត្រូវមានវត្តមាននៅការិយាល័យបោះឆ្នោត នៅម៉ោង ០៦:០០នាទីព្រឹក ដោយនាំមកជាមួយនូវឧបករណ៍ សម្ភារ ឬគ្រឿងបរិក្ខារ និងឯកសារបោះឆ្នោត ហើយការបោះឆ្នោតត្រូវបើកដំណើរការ នៅម៉ោង ០៧:០០ព្រឹក និងបិទនៅម៉ោង ១៥:០០រសៀល រួចត្រូវចាប់ផ្តើមរាប់សន្លឹកឆ្នោតរហូតដល់ចប់សព្វគ្រប់ជាស្ថាពរ ។

ភ្នាក់ងារសន្តិសុខបោះឆ្នោត ដែលមានភារកិច្ចការពារការិយាល័យបោះឆ្នោតនីមួយៗ ត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងឲ្យបានត្រឹមត្រូវ និងមានពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប ត្រូវប្រញាប់ទៅកាន់ការិយាល័យបោះឆ្នោតដែលខ្លួនត្រូវការពារ នៅមុនម៉ោង ០៦:០០នាទីព្រឹក ដើម្បីពិនិត្យទីតាំងភូមិសាស្ត្រឲ្យបានគ្រប់ជ្រុងជ្រោយ និងចាត់វិធានការការពារសន្តិសុខយ៉ាងតឹងរ៉ឹងជាទីបំផុត ។

ភ្នាក់ងារសន្តិសុខបោះឆ្នោតនេះត្រូវបានអនុញ្ញាតឲ្យចូលបោះឆ្នោត ក្នុងសម្លៀកបំពាក់ឯកសណ្ឋានកងកម្លាំងបាន ប៉ុន្តែត្រូវផ្លាស់វេនគ្នាម្តងម្នាក់ៗទៅបោះឆ្នោត ដោយធានាឲ្យមានកម្លាំងយ៉ាងតិច ០១នាក់ នៅប្រចាំការការពារ និងហាមការយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ចូលទៅក្នុងការិយាល័យបោះឆ្នោតដែលខ្លួនត្រូវបោះឆ្នោត ។ ចំពោះសមាជិកកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិគ្រប់ជាន់ថ្នាក់ដែលមិនមានភារកិច្ចគឺមិនត្រូវបានអនុញ្ញាតឲ្យទៅជិត ឬឈរក្បែរការិយាល័យបោះឆ្នោត ឬចូលទៅបោះឆ្នោតក្នុងសម្លៀកបំពាក់ឯកសណ្ឋានកងកម្លាំងបានឡើយ លើកលែងតែភ្នាក់ងារសន្តិសុខបោះឆ្នោត ឬសមាជិកកងកម្លាំងដែលមានភារកិច្ចចាំបាច់ និងត្រូវមានការអនុញ្ញាតពី គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ឬប្រធានសាមីអង្គភាពពាក់ព័ន្ធនីមួយៗ ត្រូវធ្វើបញ្ជីឈ្មោះភ្នាក់ងារសន្តិសុខបោះឆ្នោត ឬសមាជិកកងកម្លាំងដែលមានភារកិច្ចចាំបាច់ខាងលើ ជូនទៅប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ដើម្បីរៀបចំសម្របសម្រួលឲ្យកងកម្លាំងទាំងនោះបានចូលទៅបោះឆ្នោតមុន និងឆាប់បានទៅបំពេញភារកិច្ច ឬទៅការពារគោលដៅរបស់ខ្លួនវិញ ។

**៣/ ក្រោយការបោះឆ្នោត**

បន្ទាប់ពីការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវការពារគ្រប់ទីកន្លែងរក្សាទុកសម្ភារឧបករណ៍ គ្រឿងសង្ហារិម កំណត់ហេតុ ស្តីពីការរាប់សន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោត និងឯកសារសម្រាប់ដំណើរការបោះឆ្នោតទាំងមូល និងការពារការដឹកជញ្ជូនពីគោលដៅមួយទៅកាន់គោលដៅមួយកំណត់ដោយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ប្រកបដោយសន្តិសុខសុវត្ថិភាពខ្ពស់ ។

ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវប្រមូលផ្តុំកម្លាំង និងមធ្យោបាយរបស់ខ្លួន ដើម្បីបន្តពង្រឹងកិច្ចការការពារសន្តិសុខ សុវត្ថិភាពទូទៅនៅតាមបណ្តាគោលដៅក្នុងភូមិសាស្ត្រដែលឈរជើងរបស់ខ្លួន រហូតដល់ការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៤ ត្រូវបានបញ្ចប់សព្វគ្រប់ជាស្ថាពរ ។

ទទួលបានសេចក្តីណែនាំនេះ ប្រធានលេខាធិការដ្ឋាននៃ គ.ស.អ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកចាត់ចែងផ្សព្វផ្សាយទូលំទូលាយ និងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ។

**ជ.គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**

**ប្រធាន**

**សម្តេចក្រឡាហោម ស ខេង**

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ស៊ិក ប៊ុនហុក**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គ្រប់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត
- គ្រប់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត
- ឯកសារ-កាលប្បវត្តិ